ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍
ទេសចរណ៍សៀមរាប-អង្គរ
លេខ:..០០៤.លសរ..គ.អ.ទ.ស.......

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## ប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

សេចក្ដីសម្រេចនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដើម្បីធ្វើការគ្រប់គ្រង និងអភិវឌ្ឍន៍គោលដៅទេសចរណ៍នីមួយៗប្រកបដោយគុណភាព និងនិរន្តរភាព ស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥។

**ប្រការ២._**

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវបានបង្កើតឡើងតាមតំបន់ចំនួន៦ រួមមានដូចខាងក្រោម÷

១. តំបន់ឧទ្យានជាតិភ្នំគូលែន

២. តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី

៣. តំបន់បេតិកភណ្ឌអង្គរ

៤. តំបន់ក្រុងសៀមរាប

៥. តំបន់បឹងទន្លេសាប

៦. តំបន់ទេសចរណ៍សៀមរាបថ្មី។

ចំពោះ អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៣._**

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- សម្របសម្រួល ចាត់ចែង អនុវត្តផែនការសកម្មភាពនៃផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ សម្រាប់តំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ពង្រឹងការអភិវឌ្ឍផលិតផលទេសចរណ៍ បម្រើសេចក្ដីត្រូវការរបស់ភ្ញៀវទេសចរឱ្យបានសម្បូរបែប និងអាចផ្ដល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរក្នុងដំណើរកម្សាន្ត នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អមជាមួយការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ផ្សព្វផ្សាយតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួនទៅកាន់ទីផ្សារទេសចរណ៍ជាតិ និងអន្តរជាតិ

- ពិនិត្យ និងផ្តល់យោបល់លើគម្រោងវិនិយោគសាធារណៈ និងឯកជនបម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍ នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ជូនគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ សៀមរាប-អង្គរ
- ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- គាំទ្រជាមូលនិធិ ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ទទួលខុសត្រូវរៀបចំផែនការសកម្មភាព និងសម្របសម្រួលការអភិវឌ្ឍទេសចរណ៍នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ឱ្យស្របតាមផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥
- ពិនិត្យ សិក្សា និងលើកសំណើធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥ នៅតាមគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ឱ្យស្របតាមសភាពការណ៍ និងការវិវត្តន៍នៃវិស័យទេសចរណ៍កម្ពុជា
- មានសិទ្ធិប្រមូលចំណូលពីសកម្មភាពទេសចរណ៍ក្នុងតំបន់គោលដៅរបស់ខ្លួន ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍
- រៀបចំសូចនាករគន្លឹះសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២១-២០៣៥ សម្រាប់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ធ្វើរបាយការណ៍ការងារប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនពីប្រធានគណៈប្រតិបត្តិ និងប្រធាន គ.អ.ទ.ស.។

## ជំពូកទី២

## សមាសភាព

**ប្រការ៤._**

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ មានសមាសភាពដឹកនាំ ដូចខាងក្រោម៖

១. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ឧទ្យានជាតិភ្នំគូលែន ត្រូវដឹកនាំដោយប្រធាន១(មួយ) រូប មកពីក្រសួងបរិស្ថាន

២. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប មកពីគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប

៣. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ក្រុងសៀមរាប ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប មកពីគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប

៤. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បឹងទន្លេសាប ត្រូវដឹកនាំដោយប្រធាន១(មួយ) រូប មកពីគ្រឹះស្ថានអង្គរ

៥. អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍សៀមរាបថ្មី ត្រូវដឹកនាំដោយប្រធាន១(មួយ) រូប មកពីក្រសួងទេសចរណ៍។

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនីមួយៗ មានអនុប្រធាន និងសមាជិកមួយចំនួនទៀត មកពីក្រសួងស្ថាប័នពាក់ព័ន្ធ តាមការចាំបាច់។

សមាភាពជាក់ស្តែងរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ តាមសំណើរបស់ប្រធានគណៈប្រតិបត្តិនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដោយមានការយល់ព្រមពីក្រសួងស្ថាប័នសាមីដែលជាប្រធានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនីមួយៗ។

## **ជំពូកទី៣**

## **យន្តការអនុវត្តចំណុះឱ្យអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**

**ប្រការ៥._**

លើកលែងអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បេតិកភណ្ឌអង្គរ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរជាតិអប្សរា ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ មានការិយាល័យចំណុះចំនួន០៥ (ប្រាំ) ដូចខាងក្រោម÷

១. ការិយាល័យអភិវឌ្ឍន៍ផលិតផលទេសចរណ៍

២. ការិយាល័យផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍

៣. ការិយាល័យពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍

៤. ការិយាល័យគ្រប់គ្រងបរិស្ថាន

៥. ការិយាល័យអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់។

អង្គការលេខរបស់អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក មានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីសម្រេចនេះ។

**ប្រការ៦._**

ការិយាល័យអភិវឌ្ឍន៍ផលិតផលទេសចរណ៍ មានតួនាទីពង្រឹងការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ បម្រើឱ្យសេចក្តីត្រូវការរបស់ភ្ញៀវទេសចរណ៍ឱ្យបានសម្បូរបែប និងអាចផ្តល់បទពិសោធន៍ល្អៗ ដើម្បីជាការចងចាំដល់ភ្ញៀវទេសចរក្នុងដំណើរកម្សាន្ត ក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ដោយមានភារកិច្ចដូចខាងក្រោម÷

- សិក្សា និងរៀបចំបង្កើតសៀគ្វី និងខ្សែផ្ទើដំណើរទេសចរណ៍

- សិក្សា និងបង្កើតសារមន្ទីរអរិយធម៌
- សិក្សា និងអភិវឌ្ឍន៍ទេសចរណ៍ច្នៃប្រឌិតផ្សារភ្ជាប់នឹងឧស្សាហកម្មច្នៃប្រឌិត
- សិក្សាបង្កើត និងពង្រឹងឧបករណ៍ និងមធ្យោបាយបកស្រាយពន្យល់គោលដៅទេសចរណ៍ដល់ភ្ញៀវទេសចរ
- សិក្សាស្រាវជ្រាវ និងរៀបចំអភិវឌ្ឍន៍ទេសចរណ៍បៃតង ស្របតាមស្តង់ដាបៃតងអាស៊ាន និងកម្ពុជា
- សិក្សារៀបចំ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ម៉ាយ (MICE)
- សិក្សារៀបចំ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ជនបទ ដោយផ្អែកលើការធ្វើសមាហរណកម្មក្នុងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍជនបទ
- សិក្សារៀបចំ និងអភិវឌ្ឍន៍ផលិតផលកីឡាទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

**ប្រការ៧._**

ការិយាល័យផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍ មានតួនាទីសិក្សា និងជំរុញការផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួនទៅកាន់ទីផ្សារតំបន់ និងពិភពលោកតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ ដោយមានភារកិច្ចដូចខាងក្រោម÷

- ជំរុញ និងបង្កើនការរៀបចំចងក្រងបោះពុម្ពឯកសារ និងផ្សព្វផ្សាយទេសចរណ៍ជាភាសាបរទេសជាអាទិភាព
- សិក្សា និងជំរុញការទាក់ទាញទេសចរពីប្រភពទីផ្សាទេសចរណ៍សំខាន់
- សិក្សា និងរៀបចំផែនការបង្កើនឧត្តមភាពប្រកួតប្រជែងនៃគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- រៀបចំ និងបង្កើនកិច្ចសហការជាមួយដៃគូសារព័ត៌មានជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយគោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- ជំរុញការផ្សព្វផ្សាយទេសចរណ៍ដោយឡែករបស់ខ្លួន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (Digital Marketing)
- សិក្សា និងបង្កើតម៉ាកទេសចរណ៍សម្រាប់តំបន់ទេសចរណ៍ដោយឡែករបស់ខ្លួន អមជាមួយការប្រើប្រាស់ និងផ្សព្វផ្សាយ "កម្ពុជា : ព្រះរាជាណាចក្រអច្ឆរិយៈ - ផ្តល់ភាពកក់ក្តៅ"
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

**ប្រការ៨._**

ការិយាល័យពង្រឹងគុណភាព និងនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ មានតួនាទីរៀបចំ និងពង្រឹងគុណភាពគុណភាពឧស្សាហកម្មទេសចរណ៍ក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ដោយមានភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងពង្រឹងគុណភាពគុណភាពឧស្សាហកម្មទេសចរណ៍ ឱ្យស្របតាមស្តង់ដាកម្ពុជា និងអាស៊ាន
- រៀបចំ និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ តាមរយៈស្តង់ដាចំណាត់ថ្នាក់
- រៀបចំ និងពង្រឹងគុណភាពឧស្សាហកម្មទេសចរណ៍ តាមរយៈការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្ត
- សិក្សា និងពង្រឹងភាពធន់នៃវិស័យទេសចរណ៍ ឆ្លើយតបនឹងគ្រោះមហន្តរាយ វិបត្តិជំងឺឆ្លង និងវិបត្តិនានា

- សិក្សា និងរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ដើម្បីបង្កើនសមត្ថភាពផ្គត់ផ្គង់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- សិក្សា និងរៀបចំពង្រឹងការបណ្តុះបណ្តាលសហគ្រិនភាព គំនិតច្នៃប្រឌិត និងធុរកិច្ចក្នុងវិស័យទេសចរណ៍
- សិក្សា និងពង្រឹងការធានាសុខុមាលភាពបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍
- សិក្សា វាយតម្លៃ និងពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការអភិវឌ្ឍវិស័យទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

**ប្រការ៩.**_

ការិយាល័យគ្រប់គ្រងបរិស្ថាន មានតួនាទីសិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ដោយមានភារកិច្ចដូចខាងក្រោម÷

- សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងសំរាម និងសំណល់រឹង
- សិក្សា និងរៀបចំការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹង
- សិក្សា និងរៀបចំបង្កើតប្រព័ន្ធហិរញ្ញវត្ថុសម្រាប់កិច្ចគាំពារបរិស្ថាន
- ពង្រឹងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"
- រៀបចំ និងពង្រឹងការលើកកម្ពស់តំបន់បៃតង
- សិក្សា និងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីសម្របសម្រួល និងការពារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

**ប្រការ១០.**_

ការិយាល័យអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់ មានតួនាទីសិក្សាដើម្បីជំរុញការតភ្ជាប់ក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន ដោយមានភារកិច្ចដូចខាងក្រោម÷

- សិក្សាដើម្បីជំរុញការតភ្ជាប់ផ្ទៃក្នុង នៅក្នុងតំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- សិក្សាជំរុញការតភ្ជាប់មកកាន់តំបន់គោលដៅទេសចរណ៍ដោយឡែករបស់ខ្លួន
- សិក្សាដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ឱ្យមានភាពបត់បែន និងងាយស្រួល
- សិក្សា និងសហការរៀបចំការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតបម្រើឱ្យវិស័យទេសចរណ៍
- សិក្សាពង្រឹង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបម្រើឱ្យវិស័យទេសចរណ៍
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

## ជំពូកទី៤

## កិច្ចដំណើរការការងារ

**ប្រការ១១.**_

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធានអង្គភាព។

**ប្រការ១២._**

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬដៃគូឯកជនជាតិ និងថ្នាក់អន្តរជាតិ ឱ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**ប្រការ១៣._**

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនីមួយៗ អាចលើកសំណើចំណាយប្រចាំឆ្នាំ ដោយប្រើប្រាស់ថវិកាជាតិដោយភ្ជាប់ជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់ក្រសួងស្ថាប័នសាមី។

អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែកនីមួយៗ មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់នូវធនធាន និងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥._**

អនុប្រធាន សមាជិក គ.អ.ទ.ស. គណៈប្រតិបត្តិ អនុគណៈកម្មការ លេខាធិការដ្ឋាននៃ គ.អ.ទ.ស. និងអង្គភាពក្រោមចំណុះ គ.អ.ទ.ស. ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍**

**ទេសចរណ៍សៀមរាប-អង្គរ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ**នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៥
- ឯកសារ កាលប្បវត្តិ